# កិច្ចប្រជុំលើកទី១១

## របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

សាលប្រជុំក្រសួងមហាផ្ទៃ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៦

# វឌ្ឍនភាព និងបញ្ហាប្រឈមសំខាន់ៗ

## នៃការអនុវត្តផែនការអនុវត្តផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៥ របស់គ.ជ.អ.ប.

បទបង្ហាញដោយ ៖ ឯកឧត្តម **លេង វី** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក គ.ជ.អ.ប.

# មាតិកា

I. សេចក្តីផ្តើម

II. វឌ្ឍនភាពសំខាន់ៗ

III. បញ្ហាប្រឈម

VI. ស្ថានភាពហិរញ្ញវត្ថុ

# I - សេចក្តីផ្តើម

- ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប គឺជាផែនការអនុវត្តឆ្នាំទី១នៃផអ៣ទី២
- ផែនការនេះ បានកំណត់នូវ៖
  - ចំណុចដៅជាអាទិភាពចំនួន២០
  - ថវិកាចំណាយសរុបចំនួនប្រមាណ**៣២៦**លានដុល្លារ (**ថវិការដ្ឋចំនួនប្រមាណ៨៥% និងថវិកាគាំទ្រពីដៃគូចំនួនប្រមាណ១៥%**)
  - ស្ថាប័នអនុវត្តគឺ ក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិចំនួន**២១** និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់

# II - វឌ្ឍនភាពសំខាន់ៗ

- ជារួម ក្នុងចំណោមចំណុចដៅជាអាទិភាពចំនួន២០ មានចំណុចដៅចំនួន១៦ ឬស្មើនឹង ៨០%ត្រូវបានអនុវត្ត និងបានសម្រេចតាមចំណុចដៅទាំងស្រុង ឬស្ទើរតែទាំងស្រុង

| សមិទ្ធផលរំពឹងទុក | ចំនួនចំណុចដៅជាអាទិភាព | ចំនួនចំណុចដៅដែលបានអនុវត្ត | ភាគរយ |
|---|---|---|---|
| ១. ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ | ៣ | ២ | ៦៧ |
| ២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ | ៦ | ៥ | ៨៣ |
| ៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | ៣ | ៣ | ១០០ |
| ៤. ការផ្ទេរមុខងារ និងធនធាន | ៣ | ៣ | ១០០ |
| ៥. វិមជ្ឈការហិរញ្ញវត្ថុ | ៥ | ៣ | ៦០ |
| **សរុប** | **២០** | **១៦** | **៨០** |

# II - វឌ្ឍនភាពសំខាន់ៗ (ត)

## ១. ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់៖

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

១. ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាន

- ✓ *បានសិក្សា និងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រទំនាក់ទំនងស្តីពីការចែករំលែកព័ត៌មាន*

២. ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប

- ✓ *បានសិក្សា និងកែលំអនីតិវិធីហិរញ្ញវត្ថុរបស់លេខាធិការដ្ឋានក្នុងការផ្តល់ថវិកាគាំទ្រដល់ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ*
- ✓ *បានរៀបចំសេចក្តីព្រាងនៃសេចក្តីណែនាំស្តីពីនីតិវិធីរៀបចំគោលនយោបាយ ដើម្បីធានាដល់ការលើកកម្ពស់ភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានា*
- ✓ *បានកែលំអនីតិវិធីកិច្ចប្រជុំរបស់ លេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយស្ថាប័នអនុវត្ត*
- ✓ *បានសិក្សាវាយតម្លៃស្ថានភាពការងាររបស់មន្ត្រី និងទីប្រឹក្សាបច្ចេកទេសទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរៀបចំផែនការបុគ្គលិកសម្រាប់ឆ្នាំ២០១៦ ព្រមទាំងពិនិត្យកែសម្រួលតួនាទីភារកិច្ចរបស់មន្ត្រី និងទីប្រឹក្សាទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។*

# II - វឌ្ឍនភាពសំខាន់ៗ (ត)

## ២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

៣. ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម

- ✓ *បានបង្កើតគណៈកម្មាធិការគ្រប់គ្រង និងបានអនុវត្តការងារគណនេយ្យភាពក្នុងស្រុកចំនួន២៧*

៤. ការរៀបចំ និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក

- ✓ *បានរៀបចំសេចក្តីណែនាំ និងគំរូវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក*
- ✓ *ក្រុង ស្រុកចំនួន៥៤បានរៀបចំ និងអនុម័តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួន*

៥. ការពង្រឹងសមត្ថភាពសមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

- ✓ *បានបង្កើតអគ្គលេខាធិការដ្ឋានរួម និងបានរៀបចំយុទ្ធសាស្ត្រថ្មីដើម្បីពង្រឹងប្រសិទ្ធភាពការងារ*

៦. ការរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានីខេត្ត និងក្រុងស្រុកខណ្ឌ

- ✓ *បានរៀបចំ អនុម័ត និងបានបណ្តុះបណ្តាល*

៧. ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង

- ✓ *បានរៀបចំកម្មវិធីតាមប្រព័ន្ធកុំព្យូទ័រ  និងបានអនុវត្តសាកល្បងនៅតាមក្រុង ស្រុកចំនួន១០។*

# II - វឌ្ឍនភាពសំខាន់ៗ (ត)

## ៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

៨. ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

- ✓ *បានរៀបចំបញ្ចប់សេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ*

៩. ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីការងារយេនឌ័រ

- ✓ *រដ្ឋបាលខេត្តចំនួន៣បានរៀបចំបញ្ចប់វគ្គបណ្តុះបណ្តាល និងខេត្តមួយចំនួនផ្សេងទៀតកំពុងដំណើរការរៀបចំជាបន្តបន្ទាប់*

១០.ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត

- ✓ *រដ្ឋបាលរាជធានី ខេត្តទាំងអស់បានរៀបចំបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស*
- ✓ *មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្តបានចាប់ផ្តើមដំណើរការតាមតួនាទីដែលបានកំណត់*

# II - វឌ្ឍនភាពសំខាន់ៗ (ត)

## ៤. ការផ្ទេរមុខងារ និងធនធាន

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

**១១.ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ✓ *បានផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក*
- ✓ *បានធ្វើប្រតិភូកម្មមុខងារការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅឱ្យខេត្ត ក្រុង ស្រុក ឃុំ (ខេត្តបាត់ដំបង)*
- ✓ *បាន និងកំពុងសិក្សាដើម្បីរៀបចំលិខិតបទដ្ឋានសម្រាប់ការផ្ទេរមុខងារគ្រប់គ្រងការអប់រំបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ*
- ✓ *បាននិងកំពុងផ្ទេរសាកល្បងនូវមុខងារគ្រប់គ្រងមណ្ឌលសុខភាព ការថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងសេវាអប់រំអនាម័យជនបទ*

**១២.ការផ្ទេរមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាទីប្រជុំជនឱ្យទៅរដ្ឋបាលក្រុង**

- ✓ *បានសិក្សាអំពីលទ្ធភាព និងជម្រើសនានាក្នុងការផ្ទេរមុខងារសេវាទីប្រជុំជនពីរដ្ឋបាលខេត្តឱ្យទៅរដ្ឋបាលក្រុង*

**១៣.ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពីមុខងារជាជម្រើស និងសេវាសង្គម**

- ✓ *បានរៀបចំបញ្ចប់សេចក្តីព្រាងឯកសារបច្ចេកទេស*

# II - បញ្ហានភាពសំខាន់ៗ (ត)

## ៥. វិមជ្ឈការហិរញ្ញវត្ថុ៖

ចំណុចដៅជាអាទិភាពដែលបានអនុវត្ត និងសម្រេចបានតាមចំណុចដៅរួមមាន៖

១៤.ការកែលំអប្រព័ន្ធ និងនីតិវិធីអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់

- ✓ *បានរៀបចំក្រុមការងារអន្តរក្រសួងដើម្បីចុះសិក្សាស្រាវជ្រាវ ប្រមូលនូវព័ត៌មាន និងកំណត់នូវបញ្ហាប្រឈមនានា ដើម្បីឈានទៅធ្វើការកែលំអប្រព័ន្ធ និងនីតិវិធីនៃការផ្ទេរ និងការប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យកាន់តែល្អប្រសើរ*

១៥.ការបង្កើតលេខាធិការដ្ឋានទទួលបន្ទុកមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

- ✓ *បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះនឹងផ្តល់ក្របខណ្ឌគតិយុត្តសម្រាប់ការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ*

១៦.ការកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ✓ *បានរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សម្រាប់ការប្រឹក្សាយោបល់។*

# III - បញ្ហាប្រឈម

- ការយឺតយ៉ាវនៃការរៀបចំកែលំអ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចជាហានិភ័យដ៏ចម្បងមួយក្នុងការជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង ចាត់ចែង ប្រើប្រាស់ធនធាន និងអនុវត្ត តួនាទីរបស់ខ្លួនស្របតាមក្របខណ្ឌច្បាប់ លិខិតបទដ្ឋាន និងស្តង់ដារដែលបានកំណត់
- យុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងនៅពុំទាន់បានកែលំអឱ្យបានច្បាស់លាស់ និងដាក់ឱ្យអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធនៅឡើយ។ នេះគឺផលប៉ះពាល់ជាអវិជ្ជមានមួយដល់ការចែករំលែកព័ត៌មាន និងការបង្កើនការយល់ដឹងជាទូទៅនៃកិច្ចដំណើរការកំណែទម្រង់នៅក្នុងចំណោមអ្នកពាក់ព័ន្ធនានា។
- ភាពយឺតយ៉ាវនៃការរៀបចំយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ក៏ជាបញ្ហាប្រឈមដែលត្រូវ ផ្តោតការយកចិត្តទុកដាក់ដោះស្រាយ ដើម្បីធានាឱ្យមានយន្តការផ្ទេរថវិកាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រង ចាត់ចែង និងអនុវត្តនូវមុខងារនានាដែលបានផ្ទេរឱ្យ។

# III - បញ្ហាប្រឈម (ត)

- ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រទៅលើផ្នែកអភិវឌ្ឍន៍នៃមូលនិធិក្រុង ស្រុក ឱ្យបាន០.៥%ធៀបទៅនឹងចំណូលចរន្តប្រចាំឆ្នាំសរុបរបស់ថវិការដ្ឋ គឺជាចំណុចដៅជាអាទិភាពមួយនៃ ផ.ស.ថ ឆ្នាំ២០១៥ និងផអ៣ទី២។ ផ្អែកតាមការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍នាពេលកន្លងមក យើងអាចវាយតម្លៃបានថា ចំណុចដៅនេះពុំបានសម្រេចតាមការកំណត់ឡើយ។ ដូច្នេះ ភាពមានកម្រិតនៃមូលនិធិក្រុង ស្រុក គឺ**ជាបញ្ហាប្រឈមជាគន្លឹះមួយ** ក្នុងការជំរុញ និងអភិវឌ្ឍក្រុងស្រុកឱ្យក្លាយជារដ្ឋបាលមូលដ្ឋានមានធនធានសមស្របសម្រាប់ការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍនានាទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកសេវាសង្គមនៅមូលដ្ឋាន និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

# IV. ស្ថានភាពហិរញ្ញវត្ថុ

- ស្ថានភាពចំណាយនៃកញ្ចប់ថវិការួមដែលជាការរួមចំណែកពីដៃគូអភិវឌ្ឍន៍សំខាន់ៗ សម្រាប់គាំទ្រការងារកំណែទម្រង់មានឆ្លុះបញ្ចាំងក្នុងតារាងខាងក្រោម (គិតជាដុល្លារ)៖

| **ពិពណ៌នាមុខចំណាយ** | **ថវិកាគ្រោង** | **ចំណាយ** | **%ចំណាយ** |
|---|---|---|---|
| សមិទ្ធផលរំពឹងទុកទី១ | 722.687 | 421.887 | 58% |
| សមិទ្ធផលរំពឹងទុកទី២ | 509.311 | 251.513 | 49% |
| សមិទ្ធផលរំពឹងទុកទី៣ | 857.966 | 707.978 | 83% |
| សមិទ្ធផលរំពឹងទុកទី៤ | 1,466.639 | 754.630 | 51% |
| សមិទ្ធផលរំពឹងទុកទី៥ | 303.445 | 213.130 | 70% |
| បុគ្គលិក និងប្រតិបត្តិការ | 8.005.926 | 6.911.762 | 86% |
| **សរុបរួម** | **11.865.974** | **9.260.899** | **78%** |

# សូមអរគុណ